# រឿងម្ចាស់ដែនដី

ញ៉ែម សុផាត

## Lord of the Land

By Nhem Sophath

លោករស់នៅខេត្តតាកែវ។ បច្ចុប្បន្នជាគ្រូបង្រៀន នៅវិទ្យាល័យសម្តេចឪ ខេត្តតាកែវ និងកំពុង សិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកវិទ្យាសាស្ត្រអប់រំ។ នៅឆ្នាំ២០០៦នេះ លោកទទួលបាន ចំណាត់ថ្នាក់លេខ៣ ពីសមាគមអក្សរសិល្ប៍ន្ធ ហាច ផ្នែករឿងខ្លី មានចំណងជើងថា៖ *ម្ចាស់ដែនដី*។

*ព្រះអាទិត្យចាប់បំភ្លឺផែនដី ដោយរស្មីក្រហមព្រឿងៗឯទិសបូព៌។ ថ្ងៃនេះ មេឃស្រឡះល្អ ហាក់ជួយអបអរហ្វូងគោព្រៃដែលជាម្ចាស់ដែនដីនេះ។ ហ្វូងគោកញ្ជ្រោលសើចក្អាកក្អាយសប្បាយចិត្តគ្រប់ៗគ្នា ដោយមានសមាជិកថ្មីកើតច្រើន នារដូវកាលនេះ។*

*មេហ្វូងគោព្រៃឈរកៀកកើយជិតប្រពន្ធ ហើយងាកទៅមេហ្វូងមួយទៀត ដោយនិយាយ៖*

*ល្បងឡើង! កូនល្បងដូចល្បងដល់ហើយ ទាំងរូបរាង ទាំងមុខ ទាំងមាត់ ដូចបេះដាក់តែម្តង ល្បងឯងប្រសប់មែនទែន!*

*បូកឯងក៏មិនអន់ដែរ កូនឯងក៏ស្អាតបាតណាស់ដែរតើ។ ទៅថ្ងៃក្រោយមានតែពួកវាទេដែលអាចជួយឲ្យពូជអម្បូរយើងរីកចម្រើន...*

*មែនហើយល្បង! ក្មេងៗប្រាកដជាអាចបន្តវេន និងជំនួសដៃជើងពួកយើងមិនខាន។ (និយាយបណ្តើរ មេហ្វូងបោះជំហានមួយៗ ទៅឈរជិតប្រពន្ធលិឈថ្មមៗ) រួចសួរ៖*

*អូន! មិនអីទេឬ?*

*មិនអីទេ តែអស់កម្លាំងបន្តិច... កូនយើងគួរឲ្យស្រឡាញ់ណាស់! បងត្រូវមើលការពារវាឲ្យហ្មត់ចត់ផង(មេគោឆ្លើយដោយងាកមើលកូន ដែលប្រឹងងើបឈរ)។*

*បងដឹងហើយ!(អាបូកមេហ្វូងតបទៅប្រពន្ធ)*

*ហ្វូងសត្វក៏ដូចមនុស្សដែរ បែងចែកបក្ស ពួក ក្រុម ហ្វូង... គោក្នុងជ្រលងព្រៃនេះ បានចែកគ្នាជាពីរហ្វូង។ មេហ្វូងមួយមានមាឌធំខ្ពស់ សម្បុរសហៅអាឡើង ឯមេហ្វូងមួយទៀតជាគោបា មាឌក្រអាញ ពណ៌ខ្មៅរលើបឈ្មោះអាបូក។*

*មេហ្វូងគោទាំងពីរ មានសម្បុរខុសគ្នាក៏ពិតមែន ប៉ុន្តែពួកវារស់នៅដោយចុះសម្រុងជាមួយគ្នា ដឹកនាំហ្វូងគោតែរៀងៗខ្លួន។ ហ្វូងគោស្រឡាញ់គ្នាណាស់។ ចេះជួយគ្នាទៅវិញទៅមក ព្រោះពួកវាជាពូជគោព្រៃតែមួយ។*

ថ្ងៃខែចេះតែកន្លងផុតទៅ។ ឆ្លងកាត់រយៈពេលដ៏យូរនៃជីវិតរស់នៅក្នុងជ្រលងព្រៃភ្នំនេះ គោដែលមិនចេះដាំដុះ មិនអាចរកស្មៅបំពេញក្រពះបានស្រួលទេ។

ដែនដីរបស់គោព្រៃ ដែលពីមុនធ្លាប់តែរស់នៅដោយសម្បូរសប្បាយ ឥឡូវប្រែទៅជាហួតហែង ដោយសារធម្មជាតិមិនអំណោយផលដូចមុនៗ ភាពរាំងស្ងួត ធ្វើឲ្យវាលស្មៅដែលធ្លាប់តែខៀវស្រងាត់ ប្រែជាសោះកក្រោះ ក្តៅឆេះ។ នៅឯជើងភ្នំក្បែរដែនដីនេះ មានចចកមួយហ្វូងរស់នៅ។ សត្វនេះ តែងតែយាយីដល់ហ្វូងគោជារឿយៗ។ កូនគោតូចៗ បាត់ម្តងមួយៗពីហ្វូង។ ចំណែកនៅក្នុងស្ទឹង ដែលជាប្រភពទឹកតែមួយគត់សម្រាប់ហ្វូងគោ មានហ្វូងក្រពើរស់នៅ លបខាំប្រហារជីវិតគោព្រៃ ដែលទៅអាស្រ័យទឹកនោះ។

គោមួយចំនួន បានក្លាយជាចំណីរបស់ក្រពើ មួយចំនួនទៀតក្លាយជាចំណីរបស់ចចក។ ជីវិតគោជាច្រើនបានស្លាប់រាល់ៗថ្ងៃ។ ភាពក្រីក្រ ទុរគត អត់ស្មៅ ចំបើង អត់ទឹក ចេញទៅណាមិនបាន ធ្វើឲ្យហ្វូងគោបែកខ្ញែកគ្នា រករស់ក្នុងទឹកដីរបស់ខ្លួនតាមមេ តាមបាតែរៀងៗខ្លួន។

សេចក្តីស្រេកឃ្លាន កាន់តែមករួបរឹតជីវិតហ្វូងគោព្រៃជារឿយៗ។ គោខ្លះដាច់ចិត្តចូលទៅរកស្មៅក្បែរដែនដីនៃហ្វូងចចក ទោះបីដឹងថា មានគ្រោះថ្នាក់បែបណាក៏ដោយ។ ឯគោព្រៃខ្លះទៀត ឆ្មៀតលាក់បាំងទីដែលមានល្បាស់ព្រេច ទីដែលមានចំណីទុកសម្រាប់តែខ្លួនឯង និងកូនចៅ ឬក្រុមខ្លួនប៉ុណ្ណោះ។ គោខ្លះដើររកស្មៅទៅទីឆ្ងាយៗដាច់សង្វែង ទើបប្រទះអាហារ អាចបំពេញក្រពះខ្លះ។

ភាពលំបាក និងសេចក្តីវេទនាក៏កើតមានឡើង។ ភាពអត់ឃ្លាន បានធ្វើឲ្យហ្វូងគោមានចិត្តរង្កៀសនឹងគ្នា បែកបាក់សាមគ្គី គ្មានការយោគយល់អធ្យាស្រ័យគ្នាឡើយ...

ស្ថិតក្នុងសភាពបែបនេះ មេហ្វូងគោព្រៃទាំងពីរ ខិតខំបង្រួបបង្រួមសមាជិករបស់ខ្លួន និងរកវិធីដោះស្រាយ។ តែគួរឲ្យស្តាយ ពួកវាមិនអាចយកឈ្នះ ឬកែច្នៃល័ក្ខខ័ណ្ឌធម្មជាតិបានឡើយ។ ពេលនេះ អ្វីៗបានត្រឹមតែបណ្តោយតាមយថាកម្មប៉ុណ្ណោះ។

ព្រះសុរិយាទន់ទាប រៀបលិចចោលទ្វីបលោកទៅហើយ ថ្មើរណេះ ហ្វូងគោនាំគ្នាដើរសំដៅទៅស្ទឹង រកទឹកផឹកបំពេញពោះមុននឹងចូលសយ្យា។ មេគោ ជាប្រពន្ធអាបូក បណ្តើរកូនឆ្ងាយពីប្តី និងហ្វូងខ្លួន សំដៅទៅស្ទឹងមុនគេ។ ដើរបណ្តើរតឿនកូនបណ្តើរៈ

ដើរឲ្យលឿនឡើងកូន ឆាប់ដល់ស្ទឹង ព្រោះថ្ងៃជិតលិចហើយ!

ខ្ញុំមិនទាន់ឆ្អែតទេម៉ែ!(វាឆ្លើយបណ្តើរ មាត់បិចស៊ីស្មៅដែលដុះរិចៗតាមដំបូកបណ្តើរ)

*កូនគោដែលស៊ីស្មៅមិនបានពេញពោះ និយាយទៅមេវាទៀតៈ*

*ស្រុកយើងឥឡូវ ម៉េចក៏ខ្សត់ទៅៗអ៊ីចឹងម៉ែ! ភ្លៀងក៏គ្មាន អាហារក៏កាន់តែហោចទៅៗ ម្នាក់ៗហូបមិនឆ្អែតគ្រប់គ្នា។ អ្នកខ្លះប្រថុយជីវិតជាមួយឆ្កែចចកទៅរកស៊ីឆ្ងាយៗ រហូតស្លាប់ខ្លួនក៏មាន។*

*មេគោរីករាយណាស់ ដោយឃើញកូនចេះគិតគូរដូចនេះ។ ពីរនាក់ម៉ែកូនជជែកគ្នាបណ្តើរ ដើរតម្រង់ស្មឹងបណ្តើរ។ មិនយូរប៉ុន្មាន ម៉ែកូនគោព្រៃបានមកដល់មាត់ស្មឹង។ រំពេចនោះ កូនគោព្រៃក្រឡេកឃើញក្រុមគោព្រៃមួយក្រុម កំពុងស៊ីល្បាស់ព្រេច វានឹកអរព្រួចដោយឃ្លានផង ក៏ស្ទុះចូលទៅ...*

*ទៅដល់ កូនគោមិនបង្អង់ឡើយ វាបម្រុងស៊ីស្លឹកព្រេចនោះ តែមិនទាន់បានស៊ីផងស្រាប់តែសូរប៉ឹសៗ...! កូនគោខ្ទាតចេញពីគុម្ពព្រេច ដោយកម្លាំងវ័ធយ៉ាងខ្លាំងរបស់អាដាង ដែលជាមេក្រុមនៃហ្វូងនេះ។*

*កូនគោប្រឹងងើបទាំងឈឺផ្សា។ អាដាងសម្លក់ថ្មៃ ហើយគំហកទៅកូនគោៈ*

*អាល្អិត! នេះជាចំណីរបស់អញ អ្ហែងដឹងទេ?*

*កូនគោដែលទើបត្រូវពីរ បីស្នែងប្រឹងឈរទប់ដំហរ រួចតបទៅវិញយ៉ាងរាបសាៈ*

*ខ្ញុំដឹងថាជារបស់ពូហើយ! តែសូមពូឲ្យខ្ញុំធីផង។*

*ស្អី! ឲ្យឯងស៊ី? ឲ្យឯងស៊ី គឺអញលូង់ហើយ...*

*គោមួយក្នុងក្រុម គំហកបណ្តេញកូនគោៈ*

*អ្ហែងដឹងទេ ស្រុកឥឡូវខ្សត់ណាស់ ស្មៅក៏មិនដុះ ស្លឹកឈើក៏មិនលាស់ ទម្រាំតែរកបានប៉ុណ្ណេះ អញប្រឹងស្ទើរស្លាប់។ ចំណែកអ្ហែងអាងស្អី? ចាំតែស៊ីស្រាប់ៗនោះ។ ទៅ! ចេញទៅ! កុំសង្ឃឹមថាបានស៊ីឲ្យសោះ។*

*កូនគោឈឺផង ភ័យផង ស្រែកយំម៉ាម៉ា... ហៅមេរបស់វា។ ឮសំឡេងកូនយំ មេគោដើរយ៉ាងលឿនទៅមើល។ ពេលដល់ជិតកូនក៏សួរៈ*

*ម៉េចក៏យំកូន មានរឿងអី?*

*ហៀបនឹងតបទៅមេហើយ ស្រាប់តែអាដាងមេក្រុម ស្រែកដំឡើងឫទ្ធិខ្លាំងៗៈ*

*វានេះឥតមារយាទណាស់ មិនដឹងអាងអី បានជាព្រហើនហ៊ានស៊ីព្រេចយើង...? ក្មេងបែបនេះ ត្រូវប្រដៅខ្លះទើបបាន!*

*ឮសម្តីក្រអឺតរបស់អាដាង ដែលមិនយល់មុខខ្លួនជាប្រពន្ធមេហ្វូង ក៏កើតក្តីក្តៅមួម៉ៅឆេវ*

ធ្លួលដល់ច្រមុះ ហើយតបទៅវិញខ្លាំងៗ៖

ឯងថ្មើមធំម្ល៉េះ! ហ៊ានធ្វើបែបនេះ ដោយមិនយោគយល់ដល់ប្ដីយើង ដែលជាមិត្តភក្តិរបស់មេកោយពួកឯង...

មិនទាន់ផុតសម្ដីមេគោស្រួលបួលផង អាដាងស្រែក៖

យោគយល់អ្វី៎ះ! សម័យឥឡូវ នរណាក៏គិតពីខ្លួនឯងដែរៗ ពីមុន និងពេលនេះ មិនដូចគ្នាទេៗ អ្នកស្រីត្រូវដឹង យើងឥឡូវកំពុងត្រដររស់ យើងមិនខ្វល់ពីឧត្តមគតិ ពីច្បាប់ ពីសិទ្ធិអីទេៗ យើងដឹងត្រឹមថា ថ្ងៃនេះមានស៊ី យើងស៊ីឲ្យឆ្អែតៗ យកល្អ អ្នកស្រីឆាប់នាំកូនចេញពីទីនេះទៅ... ប្រយ័ត្នកូនចៅខ្ញុំទ្រាំមិនបាន...

ពាក្យគំរាមនេះ ប្រៀបបាននឹងចាក់ប្រេងលើភ្លើង មេគោមិនស្មានថា ក្រុមគោដ៏តូចនេះ មិនយោគយល់ដល់ខ្លួន ដែលជាប្រពន្ធមេហ្វូង ហើយពួកវាថែមទាំងហ៊ានប្រមាថខ្លួនថែមទៀតៗ ទ្រាំពុំបាន ក៏តបទៅវិញយ៉ាងទ្រគោះ៖

ពួកអារមិលគុណ! ពួកអ្ហែងមិនដឹងខ្ពស់ទាបសោះៗ ពេលជួបអាសន្នអន់ក្រ ពួកអ្ហែងបែរជាគ្រាន់បើ សូម្បីកូនយើងមកក្បែរមិនទាន់បានប៉ះមួយម៉ាត់ផង ក៏ឯងរ័ធវាស្ទើរស្លាប់ ពួកអាសត្វជាន់ក្រោយឯងនេះ នៅក្នុងព្រៃ ព្រៃមែន មិនដឹងល្អអាក្រក់សោះ...!

មិនបាច់និយាយច្រើនទេ! ឆាប់ថយចេញទៅ បើចង់សុខ(អាដាងគំរាម)

យើងមិនទៅ! អាអ្ហែងចង់ធ្វើស្អី?(មេគោតបទាំងកំហឹង)

ឃើញជម្លោះបែបមិនស្រួល កូនគោដើរមកក្រោមពោះមេវា ហើយឃាត់៖

បានហើយម៉ែ! តោះយើងទៅវិញៗ

ម៉ែមិនទៅណាទេ! ចាំមើលពួកអាគម្រក់អស់នេះ វាហ៊ានធ្វើស្អីយើង?

មេគោនិយាយបណ្ដើរ ដើរចូលទៅក្នុងក្រុមអាដាងបណ្ដើរៗ ឃើញឥរិយាបថប្រពន្ធមេហ្វូងគោខេងរ៉ែងដូច្នេះ អាដាងរឹតតែមានកំហឹង បើកភ្នែកសម្លក់ថ្មេរួចកំហែង៖

ល្មមៗបានហើយអ៊ើយ តិចលោយើងទ្រាំមិនបាន!

ល្បង! មីហ្នឹងឆ្កួតហើយ ប្រដៅវាឲ្យដឹងដៃម្ដងទៅ... កុំឲ្យវាក្អេងក្អាងទៀត(សមាជិកក្នុងក្រុមបន្ថែម)ៗ

មែនហើយល្បង(គោមួយទៀតបន្ទរ)ៗ

មេក្រុមឮពាក្យញុះញង់ កំពេលចូលពេញខ្លួន លែងស្គាល់ខុសត្រូវ ប្រឹងសម្ដែងឫទ្ធិ ជើងកោសដីខ្វាកៗ ហុយទ្រលោម ហក់ទៅរ័ធពេញទំហឹងៗ ចំណែកមេគោ បែរក្បាលយក

ស្នែងទប់ទល់វិញៗ រំពេចនោះ ការប្រយុទ្ធកើតមានឡើង...

នេះហើយសេចក្ដីក្រោធ ការស្រេកឃ្លាន និងទោសៈ ដែលជាកម្លាំងជំរុញឲ្យមិត្តភាព សាមគ្គីភាពរលាយបាត់បង់...

គោទាំងពីរខំប្រឹងយកឈ្នះតែរៀងៗខ្លួនៗ ឯកូនគោស្រែកយំម៉ម៉... ឃាត់មេវាឲ្យឈប់ជល់គ្នា៖

បានហើយម៉ែ! បានហើយ!(វាស្រែកឃាត់បណ្ដើរ រត់ជុំវិញលានប្រយុទ្ធបណ្ដើរ)។

ការប្រយុទ្ធពិតជាមានអ្នកចាញ់។ ស្រាប់តែគ្រាំ! បែកទឹកខ្វាយ មេគោរអិលជើងធ្លាក់ទៅក្នុងស្ទឹង ដោយកម្លាំងរុញពេញទំហឹងរបស់អាដាង។ ឃើញសភាពមិនស្រួល ក្រុមអាដាងក៏រត់គៀសខ្លួនបាត់ ដោយមិនរវល់នឹងមេគោបន្តិចឡើយ។ ឯកូនគោ ស្រែកយំហៅរកឲ្យគេជួយ ស្របពេលនឹងការមកដល់នៃហ្វូងរបស់បាវា។

ម៉ែ! ម៉ែ...! ជួយម៉ែខ្ញុំផង...(កូនគោស្រែកផង យំផង)

មេគោខំប្រវាឡើងគោក តែនៅជើងរបស់វា ដូចជាមានដង្កាប់មកកៀបជាប់ ឈឺផ្សាក្រៃលែង។ សំឡេងមេគោស្រែកម៉ៗ ដង្ហោយហៅរកអ្នកជួយយ៉ាងសង្វេគ៖

ជួយផង! ជួយខ្ញុំផង...!

អូនសម្លាញ់ប្រឹងឡើង! ប្រឹងឡើងអូន!(អាបូកជាប្ដីស្រែកទាំងកិតភ័យ ស្ទុះទៅជួយ តែត្រូវហ្វូងគោឃាត់ ព្រោះមានក្រពើហែលតម្រង់មក)។

កុំទៅ! កុំទៅអី! គ្រោះថ្នាក់ណាស់!(អាឡើងឃាត់)

ទេ! ខ្ញុំត្រូវតែទៅជួយប្រពន្ធខ្ញុំ! លែងខ្ញុំទៅ(អាបូកឆ្ងេឆ្ងា)

ហ្វូងគោឃាត់មិនឲ្យមេហ្វូងចុះទឹកជួយប្រពន្ធទេ។ ឯមេគោវិញ នៅក្នុងទឹកខំបម្រះពីមាត់ក្រពើ តែពុំរួចៗ ណាអស់កម្លាំង... ណាឃើញប្ដី និងកូនឆ្ងេឆ្ងាចង់មកជួយក៏ឃាត់៖

បងកុំមកអី...!(ស្រែកបានតែប៉ុណ្ណោះ ក្បាលវាលិចងើបៗក្នុងទឹកស្ទឹង។ ក្រពើទាញមេគោទៅរកទឹកជ្រៅ។ ដោយគ្មានសង្ឃឹមថានឹងបានរួចជីវិត មេគោស្រែកទៅប្ដីជាថ្មី) ប្ដីសម្លាញ់! មើលថែកូនឲ្យបានល្អផង...

មិនទាន់ចប់ប្រយោគផង ហ្វូងក្រពើហក់ត្របាក់មេគោពន្លិចទឹក។ គោញីប្រឹងបើកភ្នែកមើលមកកូន និងប្ដី មុននឹងលិចបាត់ក្នុងទឹក។ ឯមេហ្វូងដ៏មានអំណាច បានត្រឹមបើកភ្នែកឈរមើលប្រពន្ធដោយក្ដីអាណិតអាសូរបំផុត។ ហ្វូងគោនៅទ្រឹងដោយស្ដាយស្រណោះជីវិតគោញី ដែលធ្លាប់រស់នៅកម្សត់កម្រជាមួយគ្នា។ កូនគោនៅទួញសោកស្រែករកមេវា៖

ម៉ែ! ម៉ែ...!

កូនពុកឈប់យំទៅ! ម៉ែឯងទៅឆ្ងាយហើយ។ ពីថ្ងៃនេះទៅ យើងលែងឃើញមុខម៉ែឯងទៀតហើយ(បាគោលួងលោម លិឍអង្អែលកូន តែខ្លួនឯងវិញទឹកភ្នែករាប់សែនដំណក់ហូរឥតអាក់)។

ព្រះសុរិយាលិចបាត់ ដោយមិនអើពើនឹងសេចក្ដីសោកសង្រេង របស់ហ្វូងគោឡើយ។ ហ្វូងគោព្រៃទាំងអស់វិលមកជម្រកវិញ ជិតដាមដោយទុក្ខសោកពន់ប្រមាណ ពិសេសអាបូក និងកូន។

ផ្ទៃមេឃងងឹតសូន្យសុង។ យប់នេះ ហ្វូងគោព្រៃទាំងអស់លង់ដំណេកយ៉ាងស្កប់ស្កល់ នៅសល់តែមេហ្វូង និងកូនដែលនៅតែស្រមៃឃើញទិដ្ឋភាពកាលពីរសៀល នៅតែជិតជាប់នៅនឹងកែវភ្នែក។ មេហ្វូងកម្សត់នៅសម្រក់ទឹកភ្នែកម្នាក់ឯង រំលឹកអនុស្សាវរីយ៍ ដែលមានជាមួយប្រពន្ធ។ បាគោសម្លឹងមេឃា ដែលលម្អដោយហ្វូងផ្កាយ ក្នុងចិត្តស្ទើរតែមិនជឿរឿងរ៉ាវអាក្រក់ដែលកើតឡើងកាលពីល្ងាចមិញ។ ស្ទើរពេញមួយយប់ មេហ្វូងសញ្ជឹងគិតពីហេតុដែលនាំឲ្យប្រពន្ធស្លាប់ ដោយមិនអស់ចិត្ត អាបូកដាស់កូនសួរ៖

កូនពុក...! ហេតុអីបានជាម៉ែឯងធ្លាក់ចូលក្នុងស្ទឹង?

កូន... ដឹងពុក!(កូនគោឆ្លើយទាំងមិងមាំង)។

កូនប្រាប់ពុកមើល៍! រឿងនោះវាយ៉ាងម៉េច?

កូនគោបានប្រាប់គ្រប់រឿងទៅបារបស់វា។ គ្រាន់តែឮថាប្រយុទ្ធគ្នា វាលាន់មាត់៖

ឯងថាម៉េច? ប្រយុទ្ធគ្នា! ប្រយុទ្ធគ្នាព្រោះតែស្មឹកព្រេច។ ហ៊ឺះ! ជ្រុលពេកហើយ។ ពួកវាមិនទុកមុខទុកមាត់ឲ្យអញសោះ។ រឿងប៉ុណ្ណឹង វាហ៊ានធ្វើឲ្យប្រពន្ធអញស្លាប់។ អញមិនអត់ឱនឲ្យពួកអ្ហែងដាច់ខាត។

កំហឹងជ្រាបចូលពេញទ្រូងអាបូក។ សេចក្ដីស្រឡាញ់ ការរាប់អាន ការយោគយល់ ការរួបរួម បានរលាយបាត់អស់។ ពេលនេះ ក្នុងចិត្តនៅមានតែគំនុំសងសឹកប៉ុណ្ណោះ។ ចិត្តសែនអន្ទះសា បន់ឲ្យតែមេឃភ្លឺច្បាស់ ដើម្បីធាប់បានទៅជម្រះបញ្ជីជាមួយហ្វូងអាឡើង។

ព្រឹកនេះ ធម្មជាតិកាន់តែស្រពោនស្ងិត ដែនដីនេះកាន់តែក្ដៅហួតហែង សត្វទាំងអស់រស់ក្នុងភាពស្រេកឃ្លានគ្រប់គ្នា គោនីមួយៗចេញរកចំណីទាំងអស់សង្ឃឹម និងស្ងប់ស្ងៀម។ ដែនដីដ៏សម្បូរ ធ្លាប់ចិញ្ចឹមគោរាប់សិបក្បាល ពេលនេះប្រែជាខ្សត់ខ្សោយ និងត្រូវហ្វូងចចកឃ្លានពានឥតឈប់ឈរ។ ច្បាប់គ្រប់គ្រងដែនដី កាន់តែទន់ខ្សោយទៅៗ...

អាបូកដើរសំដៅទៅហ្វូងអាឡើង។ ឃើញអាបូកមកដល់ អាឡើងសួរពាក់ទាក់៖

ល្បងមកម្ដុំនេះដែរ? មកបរិភោគជាមួយគ្នា!

ដោយមានកំហឹង អាបូកមិនរវល់នឹងពាក្យពាក់ទាក់របស់អាឡើងឡើយ ក៏តបទៅវិញដោយសេចក្ដីក្រោធ៖

អញមិនមែនមកសុំស្មៅស៊ីទេ! អញមកនេះ ដើម្បីរកយុត្តិធម៌ឲ្យប្រពន្ធអញ...

មានរឿងអីនិយាយតាមសម្រួលទៅ ល្បងមិនបាច់ធ្វើយ៉ាងនេះទេ(អាឡើងនិយាយសម្រួលចិត្តមេហ្វូងគោពណ៌ខ្មៅ)។

ឮសំឡេងជជែកគ្នាដូច្នេះ ប្រពន្ធ កូន និងហ្វូងអាឡើងដែលនៅក្បែរនោះ នាំគ្នាចោមរោមស្ដាប់។ ប្រពន្ធមេហ្វូងសួរទៅប្ដី៖

មានរឿងអី... ឪវា?

គ្មានរឿងអីទេ! ល្បងគាត់មក...

មិនមែនមកកម្សាន្តទេ គឺយើងមករកខុសត្រូវ(អាបូកឆ្លើយទាំងកំហឹង)។

អ្នកស្ដាប់ ស្ដាប់ទៅហើយ ល្បងកាត់ចិត្តខ្លះទៅ...!(ប្រពន្ធមេហ្វូងសម្ដែងអាការៈលួងលោមថែមទៀត)

ប្រពន្ធខ្ញុំ មិនមែនសាច់ញាតិឯង ឯងថាម៉េចក៏បាន។

ល្បងទប់អារម្មណ៍ខ្លះទៅ!(អាឡើងតប)។

ពេលនេះ ស្ថានភាពពួកយើងកំពុងតែដុនដាបខ្លាំងណាស់ យើងកុំគិតពីរឿងនេះអីយើងគួរតែដោះស្រាយបញ្ហា ដែលកើតឡើងចំពោះមុខវិញ... ដូចល្បងដឹងហើយ ចចកតែងប្រហារពួកយើងរាល់ថ្ងៃ។ ស្ថិតក្នុងសភាពបែបនេះ យើងពុំគួរឈ្លោះទាស់ទែង ឬខ្វែងគំនិតគ្នាទេ។ រឿងសំខាន់ គឺរក្សាដែនដីរបស់យើង។ រឿងផ្ទាល់ខ្លួនគួរតែទុកមួយឡែកសិនទៅ...!(ប្រពន្ធអាឡើងលើកហេតុផលពន្យល់)

អញមិនរវល់អ្វីទាំងអស់! ប្រពន្ធអញស្លាប់ដោយសារកូនចៅឯង ឯងនៅនិយាយថា កុំឲ្យអញគិតពីរឿងនេះទៀត ឯងនិយាយនេះកាន់ជើងគ្នីគ្នាឯងច្បាស់ក្រឡែត។

មិនមែនទេល្បង! ប៉ុន្តែ...

ចប់សម្ដីមិនសឹងទាន់ អាបូកដែលមានកំហឹងជាប់ខ្លួនគំហកខ្លាំងៗ៖

កុំនិយាយច្រើន! ឆាប់ប្រគល់អាណា ដែលរុញប្រពន្ធអញធ្លាក់ទឹកចេញមក!

ល្បង! មិនមែនខ្ញុំមិនចង់ទេ! តែពួកវាត្រូវចចកខាំងាប់អស់ហើយ...

ឯងនិយាយបែបនេះ តាមមើលចង់លាក់បាំងយករួចខ្លួនទេដឹង...

សម្ដីចោទបំពាននេះ ធ្វើឲ្យអាឡើងអន់ចិត្តយ៉ាងខ្លាំង ក៏តបទៅវិញ៖

នែ៎ល្បង! ខ្ញុំប្រាប់ហើយថា ពួកវាងាប់អស់ហើយ! ខ្ញុំគ្មានអ្វីប្រគល់ឲ្យទេ បើល្បងមិនសុខចិត្ត ទៅរកខ្មោចពួកវាក្នុងហ្វូងចចកទៅ...

និយាយចប់ អាឡើងដើរចេញ ធ្វើឲ្យអាបូកសែនក្ដាញ់ ខឹងសម្បារយ៉ាងខ្លាំង ក៏ស្ទុះទាំងកំពោល បោលបំបុក សំដៅទៅអតីតមិត្តសម្លាញ់ទាំងកំហឹង...

ប្រយ័ត្ន...!(កូនគោស្រែកប្រាប់បាវាព្រមទាំងហក់ទៅរាំងផង) ប៊ឺស! អាឡើង និងប្រពន្ធស្រឡាំងកាំង ដោយឃើញកូនរបស់ខ្លួនប៉ើងខ្ទាតទៅបុកគល់ឈើបត់កលែងកម្រើក។

ពុទ្ធោ! កូន...!(មេរបស់វាស្រែកស្ទើរភ្ញាត់សំឡេង)

ហ្វូងគោជាកូនចៅអាឡើង រត់ព្រួសំដៅកូនគោ ដែលដាច់ខ្យល់ស្លាប់ក្បែរគល់ឈើ។ ភាពសោកសៅបានមករុំស្រោបដួងចិត្តហ្វូងគោ ពិសេសមេបារបស់វា។

អ្វីៗហួសអស់ទៅហើយ។ ជម្លោះរវាងហ្វូងគោ ឈានដល់កម្រិតធ្ងន់ធ្ងរមួយ ដែលពិបាកនឹងដោះស្រាយ។ មេគោ ឱនលិឍសពកូនទាំងទឹកភ្នែកហូរ ជាមួយនឹងសំឡេងទួញសោកស្រណោះកូន៖

កូនសម្លាញ់ កូនគួរឲ្យអាណិតណាស់! មិនគួរស្លាប់ចោលម្ដាយទាំងក្មេងដូចនេះទេ...

ហាស... ហាស... ពេលនេះពួកឯងស្គាល់ការឈឺចាប់ហើយមែនទេ?

អាបូក មិនត្រឹមតែមិនស្ដាយស្រណោះកូនគោ ដែលខ្លួនវ៉ៃស្លាប់ប៉ុណ្ណោះទេ វាថែមទាំងនិយាយចំអកឲ្យអាឡើងទៀត។ ពាក្យចំអករបស់អាបូក ធ្វើឲ្យអាឡើងខឹងខ្លាំងឡើងៗ៖

ឯងសាហាវពេកហើយ! មិនស្ដាប់ហេតុផលអីសោះ...! ឯងធ្វើឲ្យកូនយើងស្លាប់... ហ៊ឹស! ពីពេលនេះទៅ ហ្វូងគោយើងមិនអាចរស់នៅជាមួយគ្នាបានទៀតទេ...

ស្មានតែយើងចង់នៅជាមួយពួកឯងណាស់ទៅអ្ហែះ! ចិត្តដែលស្រឡាញ់រាប់អាននឹងពួកឯងរាល់គ្នា បានរលាយបាត់ តាំងពីពេលដែលប្រពន្ធយើងស្លាប់ម្ល៉េះ។ គំនុំនេះ បើមិនសងសឹក យើងមិនស្ងប់ចិត្តទេ។

អាឡើងកាន់តែធ្លួលចុងច្រមុះ រហូតដល់ទ្រាំមិនបាន ក៏បោលសម្រុកសំដៅអាបូក៖

ឯងសងជីវិតកូនយើងវិញមក...!

បាន! ចាំមើលតើនរណាខ្លាំងជាងនរណា!

ស្ទើរតែមិនចប់សម្ដី មេហ្វូងគោទាំងពីរស្ទុះចូលដល់គ្នា។ ម្នាក់ៗបញ្ចេញកម្លាំងរៀងៗ

ខ្លួន យកឈ្នះចាញ់...

ឆាកប្រយុទ្ធមេ និងមេ កូនចៅ និងកូនចៅ ប្រព្រឹត្តទៅយ៉ាងសាហាវ។ ធ្វើឲ្យកក្រើកព្រៃនៃដែនដីនេះ។ ការប្រយុទ្ធ ដែលមិនឈ្នះមិនចាញ់ ធ្វើឲ្យអាបូកដកថយ។

ក្រោយការប្រយុទ្ធ ហ្វូងគោទាំងពីរមានស្លាប់ មានរបួសទាំងសងខាង។ ភាពខ្ទេចខ្ទាំ បន្សល់ទុកនៅលើទីលាន។

ពីពេលនេះទៅ ហ្វូងគោព្រៃទាំងពីររស់នៅបែកខ្ញែកពីគ្នា។ ពុះទឹកដី ដ៏ធំចែកគ្នាកាន់កាប់ ដោយដែនដីម្ខាងជារបស់អាបូក និងម្ខាងទៀតកាន់កាប់ដោយអាឡើង។ អាណាចក្រដ៏ទូលាយ ត្រូវពុះចែកគ្នានៅចំពោះមុខមហន្តរាយ ដែលកំពុងតែមានស្រាប់។

ព្រលឹមនេះ ស្មៅដែលមានសន្សើមដក់ ជះពន្លឺផ្លេកៗដូចរស្មីពេជ្រ។ រដូវក្តៅ រុក្ខជាតិលូតលាស់បានដោយសារសន្សើមដ៏តិចតួច ដែលច្រោះព្រំនាពេលយប់។ ហ្វូងអាបូក កំពុងរកចំណីនៅជើងភ្នំ ដែលមិនអាចបំពេញក្រពះបាន ស្រាប់តែហ្វូងគោឆោឡោឡើង ដោយចចកដេញប្រហារ។ គោទាំងឡាយប្រឹងរត់គេចពីចង្កូមដ៏មុតស្រួចរបស់ចចក គោខ្លះត្រូវស្លាប់ ខ្លះត្រូវរបួសសុសសាច់ស្រែកម៉ៗ... ហៅរកគេឲ្យជួយសង្គ្រោះ។ អនិច្ចាកូនរបស់អាបូក ត្រូវចចកដេញតាមច្បាមយកជីវិត។ មុនពេលដាច់ខ្យល់ស្លាប់ កូនគោប្រឹងស្រែកហៅបារបស់វាឲ្យជួយៈ

ពុក... ជួយខ្ញុំផង!

ពេលឮសម្រែកកូន វាស្ទុះបោលសម្រុកវ៉ៃចចកពីរបីក្បាលដាច់ផ្ងាផាប់មួយរំពេច។ ដោយឃើញស្ថានការណ៍មិនស្រួលដូច្នេះ មេចចកស្រែកលូហៅគ្នាមកជួយ។ មិនយូរប៉ុន្មាន អាបូកត្រូវចចកព័ទ្ធជាប់។ ទីបំផុតជីវិតអាបូកដ៏មានឫទ្ធិ បានរលត់ទៅជាមួយប្រពន្ធ កូន...!

ឃើញមេហ្វូងបាត់បង់ជីវិត ហ្វូងគោដែលនៅសេសសល់រត់យករួចជីវិត តែរៀងៗខ្លួន ធ្វើឲ្យដែនដីផ្នែកនេះ ធ្លាក់ក្នុងកណ្តាប់ដៃហ្វូងចចក។

បន្ទាប់ពីបានកាន់កាប់ដែនដីមួយភាគធំមក ចចកកាន់តែរាតត្បាតពង្រីកអាណាចក្រថែមទៀត ក្នុងបំណងក្រសោបយកទឹកដីនេះទាំងស្រុង។ បំណងនេះ ធ្វើឲ្យហ្វូងគោប្រឈមមុខនឹងគ្រោះថ្នាក់ឥតលស់ថ្ងៃ។ ឯហ្វូងចចកវិញ ជារឿយៗតែងប្រហារហ្វូងគោ ឲ្យផុតរលត់ជីវិតជាបន្តបន្ទាប់...

អសន្តិសុខកើតមានក្នុងដែនដីរបស់ពួកសត្វ ចំណីអាហារកាន់តែខ្សត់ទៅៗ ពួកគោស្គមទ្រោមកម្លាំងគ្រប់ៗប្រាណ។ យល់ពីសភាពការណ៍មិនអាចកែខៃបាន អាឡើងកោះប្រជុំ

ពិភាក្សាគ្នាដោះស្រាយបញ្ហា។ មេហ្វូងនិយាយដោយបារម្ភៈ

ដូចអ្នករាល់គ្នាឃើញហើយ ស្ថានភាពដែនដីរបស់យើងឥឡូវគ្រោះថ្នាក់ណាស់។ ពេលនេះហ្វូងចចកចូលមកនៅលើដីនេះទៀត។ ពួកយើងមានតែស្នែង គ្មានកម្លាំងតស៊ូនឹងចចកបានឡើយ។ (មេហ្វូងគោបង្អង់បន្តិច រួចបន្ត) ខ្ញុំយល់ថា ពួកយើងគួរតែចាកចេញពីដែនដីនេះ។

មេក្រុមគោមួយឮដូចនេះ សួរបញ្ជាក់ៈ

ល្បងសម្រេចចិត្តចាកចេញពីទីនេះមែនឬ? បងមិនស្តាយទឹកដីកេរដូនតារបស់យើងទេអី? ហើយយើងនឹងទៅឯណាវិញ?

យើងមិនត្រូវបោះបង់ទឹកដីដូនតារបស់យើងទេ(មេក្រុមមួយទៀតបញ្ជាក់)។

មេហ្វូងឃើញដូច្នេះ លើកហេតុផលតបវិញៈ

យើងយល់ពីឧត្តមគតិរបស់អ្នកទាំងអស់គ្នា។ គ្មាននរណាម្នាក់ចង់ចាកចេញពីដែនដីកំណើតរបស់ខ្លួនទេ តែស្ថានភាពបែបនេះលំបាកណាស់។ ដូចអ្នកទាំងអស់គ្នាឃើញស្រាប់ ដែនដីរបស់យើងរួញបន្តិចម្តងៗ អាហារក៏ខ្សត់ កម្លាំងពួកយើងក៏ខ្សោយទៅៗ។ មិនតែប៉ុណ្ណោះ ហ្វូងចចកនៅជិតមានចង្កូមមុតស្រួចចាំតែប្រហារ។ សមាជិកយើងខ្លះត្រូវរបួសពិការ និងស្លាប់រាល់ៗថ្ងៃ។ បើយើងនៅទីនេះទៀត មានតែផ្លូវស្លាប់ប៉ុណ្ណោះ គឺស្លាប់ដោយដាច់ពោះ ឬត្រូវចចកប្រហារ...

សមាជិកក្នុងហ្វូងទាំងអស់ស្តាប់ហេតុផលមេហ្វូង...។ គោសម្គមមួយសួរៈ

តើយើងនឹងចាកចេញពីទីនេះយ៉ាងដូចម្តេចទៅលោកបង? បើនៅជើងភ្នំមានហ្វូងចចកក្នុងស្ទឹងមានក្រពើ ច្រកផ្សេងទៀតសុទ្ធតែជាជ្រោះដ៏ជ្រៅ ដែលមិនអាចឆ្លងរួច។

យើងត្រូវតែប្រថុយ មិនត្រូវនៅទីនេះរង់ចាំសេចក្តីស្លាប់នោះទេ!(គោមួយទំនងជាលេខាអាឡើងនិយាយ)។ ចំណែកគោមួយផ្សេងទៀតលើកឡើងៈ

ខ្ញុំយល់ថា យើងគួរតែសម្រុកចេញតាមដែនដីចចក នោះអាចមានសង្ឃឹមច្រើនជាង។

មិនបានទេ! ពួកយើងមិនអាចឆ្លងផុតទេ! ដែនដីចចកធំណាស់ ទម្រាំឆ្លងផុត ប្រាកដជាស្លាប់គ្មានសល់ទេ។ មធ្យោបាយមានតែមួយគត់ គឺយើងត្រូវតែសម្រុកហែលឆ្លងស្ទឹង ទើបអាចសង្ឃឹមបានរស់ ហើយហ្វូងចចក ក៏មិនអាចហែលឆ្លងអូរតាមយើងបានដែរ(មេក្រុមមួយជំទាស់)។

ទេប្អូន! ខ្ញុំមិនយល់ព្រមតាមគំនិតប្អូនទេ!(គោចំណាស់មួយជំទាស់) បើយើងហែលឆ្លង

ស្អឹង ដូចជាប្រថុយពេកហើយ ព្រោះក្នុងទឹកមានក្រពើណា។

តើមានវិធីណាអាចរំដោះជីវិតបាន? បើធ្វងស្អឹងជួបក្រពើ ឯផ្លូវគោកមានចចក បើយើងបន្តនៅទីនេះទៀតអត់អាហារ ហើយត្រូវចចកយាយីទៀត។ ហ៊ឺ... ជីវិតយើងប្រហែលជាដាច់ពូជត្រឹមនេះហើយ(មេហ្វូងត្អូញត្អែរ)។

ល្បង! ខ្ញុំមិនចុះទឹកឲ្យក្រពើស៊ីទេ ខ្ញុំសុខចិត្តធ្វងតាមច្រកហ្វូងចចកវិញ បើចចកប្រហារយើង យើងមានឱកាសតស៊ូដែរ។ តែបើធ្វងតាមស្អឹង ស្នែងយើងមិនអាចទប់ទល់នឹងក្រពើបានទេ(គោបាមួយបញ្ចេញយោបល់)។ អឺ! បើបងប្អូនណាចង់ធ្វងតាមផ្លូវគោក មកតាមខ្ញុំ។

ឈប់សិន!(មេហ្វូងស្រែកឃាត់)។ យើងកំពុងជួបឧបសគ្គ មិនគួរយើងខ្វែងគំនិត បែកបាក់សាមគ្គី ឬបែងចែកកម្លាំងគ្នាយ៉ាងនេះទេ។ ឯងធ្វើយ៉ាងនេះ មានន័យថាម៉េច?

សុំទោស! ពេលនេះ ក្រុមខ្ញុំសូមដកខ្លួនពីលោកម្ចាស់ហើយ។ អ្នកណាគិតឃើញបែបណា ធ្វើបែបនោះទៅ(មេក្រុមនិយាយដោយតឹងតែង)។

ក្នុងកាលៈទេសៈច្របូកច្របល់បែបនេះ គោមួយចំនួនអស់ជំនឿលើមេហ្វូង ពួកវាប្រកាន់យកគំនិតខ្លួនឯងជាធំ លែងស្តាប់បញ្ជាមេកោយ។ គោមួយក្រុមដែលមានជំនឿខាងអ្នកជំទាស់ បានចាកចេញទៅ។

ហ្វូងចចកដ៏កំណាចកែនគ្នាប្រហារគោព្រៃ ដែលរត់ធ្វងកាត់ដែនដីរបស់វា ស្លាប់គ្មានសល់ ហើយវានាំគ្នាសម្រុកទៅកន្លែងដែនដីរបស់គោទៀត។

ដោយឃើញស្ថានភាពមិនស្រួល មេហ្វូងបញ្ជាឲ្យដកថយរហូតដល់មាត់ស្អឹង។ ទីបំផុតទ័លច្រក។ ខាងមុខហ្វូងចចក កំពុងតែបញ្ចេញចង្កូមសស្ងាច ឯក្នុងទឹកមានក្រពើកំពុងហែលតម្រង់មក។ ដោយទ័លគំនិត មេហ្វូងស្រែកបញ្ជាម្តងទៀតទៅហ្វូងគោះ

ទាំងអស់គ្នា... ធ្វងស្អឹង!

ព្វដូច្នេះ ហ្វូងគោលោតចូលទឹកប្រូងៗ ទោះបីដឹងថាមានគ្រោះថ្នាក់ក៏ដោយ។ ពួកគោខ្លះរួចខ្លួនពីហ្វូងចចក តែត្រូវរងការវាយប្រហារពីក្រពើវិញម្តង។ ស្អរទឹកគ្រាំៗ ដោយកម្លាំងប្រហាររបស់ហ្វូងក្រពើ និងការខំប្រឹងហែលយករួចជីវិតនៃហ្វូងគោ។

ស្ថិតក្នុងស្ថានភាពបែបនេះ គ្មាននរណាអាចជួយនរណាបានឡើយ។ គោព្រៃខ្លះមានសំណាងបានឡើងដល់គោក ខ្លះក៏ត្រូវក្លាយជាចំណីរបស់ក្រពើ។

ឡើងដល់មាត់ច្រាំង ហ្វូងគោស្ទើរផុតដង្ហើម ទន់អស់ជើងដៃ។ គោខ្លះស្រែកម៉ាៗរក

ប្រពន្ធ កូន សាច់ញាតិរបស់ពួកវា។ មេហ្វូងមមែរកប្រពន្ធតែមិនឃើញ ក្នុងចិត្តដឹងច្បាស់ណាស់ថា ប្រពន្ធធ្ងន់ស្ទើងមិនផុតទេ។ ទឹកភ្នែកហូរស្រក់ដោយសេចក្ដីសោកស្ដាយ ញាតិមិត្តកូនចៅ និងនឹកសង្វេគដល់ដែនដីរបស់ខ្លួន ដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃចចក។

ក្នុងសន្និយារាត្រីដ៏លន្ទោច សំឡេងលូនៃហ្វូងចចកឮល្វើយៗ ឯក្នុងស្ទឹងវិញសាកសពគោព្រៃអណ្ដែតពាសពេញ។ អាឡើងមេហ្វូងសម្ទឹងទៅដែនដីរបស់ខ្លួន ហើយនាំហ្វូងគោព្រៃ ដែលនៅសល់ពីស្លាប់ ដើរចេញទៅទាំងក្ដីអាឡោះអាល័យ...៕